

# ថ្នាំបង្ការជំងឺ COVID-19៖ អ្វីដែលយុវវ័យស្ថិតក្រោមការចិញ្ចឹមមើលថែទាំត្រូវដឹង




## តើខ្ញុំអាចទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ប្រភេទណាខ្លះ?

- ប្រសិនបើអ្នកមានអាយុចាប់ពី 12 ឆ្នាំឡើងទៅ អ្នកអាចទទួលចាក់ថ្នាំបង្ការលំដាប់ដំបូង ដូចជា៖
  - **ប្រភេទ Pfizer៖** ផ្តល់ជូនជាចំនួន 2 ដូស ដោយមានគម្លាតពី 3 ទៅ 8 សប្តាហ៍ពីគ្នា ឬ
  - **ប្រភេទ Novavax៖** ផ្តល់ជូនជាចំនួន 2 ដូស ដោយមានគម្លាតពី 3 ទៅ 8 សប្តាហ៍ពីគ្នា ឬក៏
  - **ប្រភេទ Moderna៖** ផ្តល់ជូនជាចំនួន 2 ដូស ដោយមានគម្លាតពី 4 ទៅ 8 សប្តាហ៍ពីគ្នា។

  អ្នកក៏គួរតែទទួលចាក់ **ដូសជំរុញប្រភេទ Pfizer ឬប្រភេទ Moderna ដែលបានធ្វើឱ្យថ្មីឡើងវិញ** ក្នុងរយៈពេល 2 ខែ បន្ទាប់ពីបានទទួលចាក់ដូសលំដាប់ដំបូង ឬដូសជំរុញចុងក្រោយបង្អស់របស់អ្នក ផងដែរ។



- ថ្នាំបង្ការទាំងឡាយគឺ **មិនគិតថ្លៃ** បើទោះបីជាអ្នកមិនមានធានារ៉ាប់រងក៏ដោយ។
- អ្នកនឹងមិនត្រូវបានសួរនាំអំពីស្ថានភាពអន្តោប្រវេសន៍របស់អ្នកទេ។
- ថ្នាំបង្ការនោះអាចចាក់បានក្នុងពេលតំណាលគ្នាជាមួយនឹងថ្នាំបង្ការផ្សេងទៀត ដូចជាថ្នាំបង្ការជំងឺគ្រុនផ្តាសាយធំ (flu) ឬថ្នាំបង្ការមេរោគដែលបង្កឱ្យមានឬស្ស (HPV) ផងដែរ។

## ហេតុអ្វីត្រូវចាក់ថ្នាំបង្ការសម្រាប់ជំងឺ COVID-19?



- ការទទួលចាក់ថ្នាំបង្ការឱ្យបានគ្រប់ចំនួនដូសតាមការណែនាំ (រួមទាំងដូសជំរុញ) គឺជាវិធីល្អបំផុតដើម្បី **ការពារខ្លួនអ្នក**។
- មនុស្សវ័យក្មេងជាច្រើនដែលឆ្លងមេរោគ COVID-19 មានរោគសញ្ញាកម្រិតស្រាល ឬមិនមានរោគសញ្ញាតែម្តង។ ប៉ុន្តែ **មនុស្សខ្លះអាចធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ** ឬមានបញ្ហាសុខភាពដែលអាចមានរយៈពេលវែង ផងដែរ។
- សូម្បីតែមនុស្សដែលមានសុខភាពល្អ ហើយដែលមិនមានបញ្ហាសុខភាពប្រចាំកាយក៏អាចនឹងត្រូវចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ ឬមានបញ្ហាសុខភាពរយៈពេលវែងផងដែរ។ មិនមានវិធីណាមួយដែលអាចប្រាប់ឱ្យយើងដឹងមុនថាតើបញ្ហាទាំងនេះនឹងកើតឡើងចំពោះអ្នក ឬអត់នោះទេ។ ការទទួលចាក់ថ្នាំបង្ការអាច **កាត់បន្ថយហានិភ័យរបស់អ្នក** ពីការទទួលរងបញ្ហាទាំងនេះបាន។

## តើខ្ញុំអាចទទួលថ្នាំបង្ការបាននៅទីណា?

ថ្នាំបង្ការជំងឺ COVID-19 អាចទទួលចាក់បាននៅតាមការិយាល័យគ្រូពេទ្យ គ្លីនិក សាលារៀន និងឱសថស្ថាន ជាច្រើនកន្លែង។ សូមចូលទៅកាន់គេហទំព័រ ph.lacounty.gov/howtogetvaccinated ដើម្បីស្វែងរកទីតាំងដែលនៅជិតអ្នក។ ប្រសិនបើអ្នកមានអាយុក្រោម 18 ឆ្នាំ ត្រូវប្រាកដថាអ្នកបានសាកសួរថាតើគួរតែមានការផ្តល់ជូនកិច្ចព្រមព្រៀងអនុញ្ញាតពីឪពុកម្តាយ ឬអាណាព្យាបាល ទៅយ៉ាងដូចម្តេច។

សូមទូរស័ព្ទទៅកាន់មជ្ឈមណ្ឌលផ្តល់ព័ត៌មានអំពីថ្នាំបង្ការរបស់នាយកដ្ឋានសុខភាពសាធារណៈ (DPH Vaccine Call Center) តាមរយៈលេខ **1-833-540-0473** ឬក៏ **2-1-1** ប្រសិនបើអ្នកត្រូវការជំនួយក្នុងការស្វែងរកថ្នាំបង្ការ ឬសម្រាប់ការធ្វើដំណើរទៅទីតាំងចាក់ថ្នាំបង្ការ ឬក៏ដើម្បីស្នើសុំការចាក់ថ្នាំបង្ការនៅតាមផ្ទះ។



# ថ្នាំបង្ការជំងឺ COVID-19៖ អ្វីដែលយុវវ័យស្ថិតក្រោមការថែរក្សាមើលថែទាំត្រូវដឹង



## តើមានផលប៉ះពាល់អ្វីខ្លះ?

ផលប៉ះពាល់នៃថ្នាំបង្ការជំងឺ COVID-19 អាចរួមមាន ដូចជាការឈឺ ឡើងហើម ឬឡើងក្រហមនៅនឹងដៃ នៅនឹងកន្លែងដែលអ្នកបានចាក់ថ្នាំបង្ការនោះ មានអារម្មណ៍ចង់ក្អួត អស់កម្លាំង គ្រុនក្ដៅ គ្រុនរងា ឈឺក្បាល ឬឈឺសាច់ដុំ។ អាការៈទាំងនេះនឹងបាត់ទៅវិញក្នុងរយៈពេលប៉ុន្មានថ្ងៃក្រោយ។ មិនមែនមនុស្សគ្រប់គ្នានឹងកើតមានផលប៉ះពាល់ទាំងនេះទេ។ ផលប៉ះពាល់ផ្សេងៗគឺជាសញ្ញាដែលបង្ហាញថាប្រព័ន្ធភាពស៊ាំរបស់អ្នកកំពុងតែ **បង្កើតការការពារ**។

## តើថ្នាំបង្ការជំងឺ COVID-19 មានសុវត្ថិភាព ដែរឬទេ?

**ចាស/បាទ!** ថ្នាំបង្ការជំងឺ COVID-19 ទាំងឡាយត្រូវបានធ្វើការសាកល្បង ហើយត្រូវបានរកឃើញថាមានសុវត្ថិភាព និងប្រសិទ្ធិភាពសម្រាប់យុវវ័យ។ ថ្នាំបង្ការទាំងនេះត្រូវបានបន្តទទួលការតាមដានផ្នែកសុវត្ថិភាពយ៉ាងជិតដល់។ រហូតមកដល់ពេលនេះ **មនុស្សរាប់រយលាននាក់** បានទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ដោយសុវត្ថិភាព។ អ្នក **មិនអាចកើតមានជំងឺ COVID-19** ពីការទទួលចាក់ថ្នាំបង្ការទេ។ មិនមានថ្នាំបង្ការណាមួយមានផ្ទុកមេរោគដែលបង្កឱ្យមានជំងឺ COVID-19 នោះទេ។

ប្រតិកម្ម ឬការទាស់បែបធ្ងន់ធ្ងរ (អាណាហ្វីឡាក់ស៊ីស/anaphylaxis) អាចកើតឡើងបន្ទាប់ពីចាក់ថ្នាំបង្ការណាមួយ រួមទាំងថ្នាំបង្ការជំងឺ COVID-19 ផងដែរ ប៉ុន្តែចំណុចនេះគឺ **កម្រ** នឹងកើតមាន។ មនុស្សមួយចំនួនតូច ជាពិសេសមនុស្សភេទប្រុសដែលមានអាយុចាប់ពី 12 ឆ្នាំ ទៅ 39 ឆ្នាំ មានការរលាកដល់បេះដូង (បញ្ហារលាកសាច់ដុំបេះដូង/myocarditis និង/ឬ បញ្ហារលាកស្រទាប់ខាងក្រៅនៃបេះដូង/pericarditis) បន្ទាប់ពីបានទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 រួច។ ស្ថានភាពនេះគឺកម្រ ហើយករណីភាគច្រើនគឺមានកម្រិតស្រាល ព្រមទាំងឆាប់ជាសះស្បើយដោយការព្យាបាល និងការសម្រាក។ ហានិភ័យរបស់អ្នកចំពោះបញ្ហារលាកសាច់ដុំបេះដូង ឬបញ្ហាបេះដូងផ្សេងទៀតគឺខ្ពស់ជាងនេះ ប្រសិនបើអ្នកឆ្លងជំងឺ COVID-19 នោះ។ ការទទួលចាក់ដូសទីពីរនាពេលយូរជាងមុន (នៅរយៈពេល 8 សប្ដាហ៍) ក៏កាត់បន្ថយហានិភ័យនៃបញ្ហារលាកសាច់ដុំបេះដូង (myocarditis) ផងដែរ។

មិនមានភស្តុតាងណាមួយដែលបញ្ជាក់ថា ថ្នាំបង្ការជំងឺ COVID-19 ជះឥទ្ធិពលដល់ការលូតលាស់របស់យុវវ័យ ឬសមត្ថភាពរបស់អ្នកក្នុងការមានកូននោះទេ។

## តើអ្នកណាជាអ្នកសម្រេចចិត្តថា តើខ្ញុំអាចទទួលចាក់ថ្នាំបង្ការបាន ឬមិនបាននោះ?

ប្រសិនបើអ្នកមានអាយុចាប់ពី 18 ឆ្នាំឡើងទៅ អ្នកអាចសម្រេចចិត្តដោយខ្លួនឯងបាន! ប្រសិនបើអ្នកមានអាយុចាប់ពី 17 ឆ្នាំចុះក្រោម ហើយស្ថិតក្រោមការថែរក្សាមើលថែទាំ (foster care) នោះអ្នកផ្ដល់ការថែរក្សាមើលថែទាំរបស់អ្នក ឬសាច់ញាតិដែលថែរក្សាមើលថែទាំអ្នក ឬក៏បុគ្គលិកនៅមណ្ឌលមើលថែទាំ អាចផ្ដល់ការអនុញ្ញាតបាន ដរាបណាអ្នកយល់ព្រមដែរ។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងទៅមេធាវីរបស់អ្នកនៅ មជ្ឈមណ្ឌលផ្នែកច្បាប់របស់កុមារ (Children's Law Center) តាមរយៈលេខ 323-980-7700។

យុវវ័យដែលមានអាយុចាប់ពី 15 ឆ្នាំឡើងទៅ ហើយដែលអាចទទួលខុសត្រូវដោយខ្លួនឯង (ឧ. អនីតិជន [ជនមិនទាន់គ្រប់អាយុ] ដែលមានសិទ្ធិស្របច្បាប់ ឬដែលអាចទទួលខុសត្រូវដោយខ្លួនឯង ឬក៏បានរៀបការរួចហើយ ឬធ្លាប់បានរៀបការពីពេលមុន) អាចផ្ដល់ការអនុញ្ញាតដោយខ្លួនឯងបាន។ ពុំនោះទេ ប្រសិនបើអ្នកមានអាយុក្រោម 18 ឆ្នាំ ឪពុក ឬម្ដាយ ឬក៏អាណាព្យាបាលស្របច្បាប់ ត្រូវតែផ្ដល់ការអនុញ្ញាតឱ្យអ្នក។

## ចុះប្រសិនបើខ្ញុំចង់ចាក់ថ្នាំបង្ការ ប៉ុន្តែអ្នកថែរក្សាមើលថែទាំរបស់ខ្ញុំមិនយល់ព្រមនោះ?

ប្រសិនបើអ្នកថែរក្សាមើលថែទាំរបស់អ្នកមិនយល់ព្រមអនុញ្ញាតឱ្យអ្នកទទួលចាក់ថ្នាំបង្ការទេ សូមទាក់ទងទៅមេធាវីរបស់អ្នក។

## តើខ្ញុំត្រូវការយកអ្វីខ្លះទៅជាមួយ នៅពេលដែលខ្ញុំទៅទទួលចាក់ថ្នាំបង្ការ?

ទីតាំងចាក់ថ្នាំបង្ការមួយចំនួនតម្រូវចាំបាច់ឱ្យមានប័ណ្ណសម្គាល់ខ្លួនដែលមានរូបថត។ ប្រសិនបើអ្នកមិនមានប័ណ្ណសម្គាល់ខ្លួនដែលមានរូបថតទេ សូមទាក់ទងទៅមេធាវីរបស់អ្នក។ ជម្រើសមួយទៀតគឺត្រូវទៅកាន់ទីតាំងមួយដែលបើកដំណើរការដោយ នាយកដ្ឋានសុខភាពសាធារណៈនៃខោនធី Los Angeles (Los Angeles County Department of Public Health) ដែលនៅទីនោះមិនតម្រូវចាំបាច់ឱ្យមានប័ណ្ណខ្លួនដែលមានរូបថតនោះទេ។

**សូមពិគ្រោះជាមួយនឹងគ្រូពេទ្យ ឪពុកម្ដាយ អ្នកមើលថែទាំរបស់អ្នក ឬក៏មនុស្សពេញវ័យដែលអាចទុកចិត្តបានផ្សេងទៀត អំពីថ្នាំបង្ការជំងឺ COVID-19។ សូមសាកសួរពួកគេនូវសំណួរណាដែលអ្នកអាចនឹងមាន។**